តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# សេចក្តីថ្លែងការណ៍ព័ត៌មាន

# ក្រសួងមហាផ្ទៃ ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអង្គការតម្លាភាពកម្ពុជាក្នុងការបង្កើតឲ្យមានសាលាអភិបាលកិច្ច

**រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦** ក្នុងបំណងរួមចំណែកជារាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ពង្រឹងសមត្ថភាពស្ថាប័នរដ្ឋនិងមិនមែនរដ្ឋ ថ្នាក់ជាតិនិងក្រោមជាតិ ក្រសួងមហាផ្ទៃ និងអង្គការតម្លាភាពកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការដែលមានរយៈពេលប្រាំឆ្នាំ ២០១៦-២០២០ ដើម្បីបណ្តុះបណ្តាលមន្ត្រីសាធារណៈអំពីអភិបាលកិច្ចល្អ សុចរិតភាព តម្លាភាព និងគណនេយ្យភាព។

ក្នុងនាមជាសាលាអភិបាលកិច្ចកម្រិតជាតិ កម្មវិធីសិក្សាប្រកបដោយភាពឯកទេស នឹងត្រូវបានរៀបចំឡើង និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីសាធារណៈនិងអ្នកពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបង្កើនចំណេះដឹង និងជំនាញសំដៅបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តការងារជាក់ស្តែង ក្នុងទិសដៅឆ្ពោះទៅការគ្រប់គ្រងធនធានជាតិនិងការផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធផល ។

អ្នកដែលនឹងទទួលការបណ្តុះបណ្តាលពីសាលាអភិបាលកិច្ចនេះ គឺរួមបញ្ចូលទាំងមន្ត្រីរដ្ឋាភិបាល ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលបំពេញការងារផ្ទាល់ក្នុងការផ្តល់សេវាសាធារណៈ ជាពិសេសអ្នកមានភារកិច្ចធ្វើគោលនយោបាយ និងធ្វើសេចក្តីសម្រេចចិត្ត។ទន្ទឹមនេះ បុគ្គលិកសង្គមស៊ីវិល និងនិស្សិតដែលមានចំណាប់អារម្មណ៍ក្នុងការសិក្សា ឬការលើកកម្ពស់ជំនាញរបស់ពួកគេទៅលើមុខវិជ្ជានេះ ក៏ត្រូវបានស្វាគមន៍ក្នុងការសិក្សានូវសាលាអភិបាលកិច្ចនេះដែរ។ ព្រមជាមួយគ្នានេះ សាលាអភិបាលកិច្ចនេះ នឹងផ្តល់ការបណ្តុះបណ្តាលចាប់ពីកម្រិតចាប់ពីថ្នាក់វិញ្ញាបនប័ត្រ បរិញ្ញាប័ត្រ និងក្រោយឧត្តម ព្រមទាំងជំនាញផ្សេងៗជាច្រើនទៀត។

លោក **ព្រាប កុល** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជាបានមានប្រសាសន៍ថា៖ "យើងខ្ញុំមានមោទនភាពណាស់ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃក្នុងការបង្កើតសាលាអភិបាលកិច្ចនេះ។ ខ្ញុំសង្ឃឹមថា សាលាអភិបាលកិច្ចនឹងក្លាយជាជំនួយដល់មន្ត្រីសាធារណៈ និងរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈ ស្របពេលនោះដែរនឹងជំនួយដល់ការកសាងសមត្ថភាពស្ថាប័ន ក្នុងការគ្រប់គ្រង និងការពារធនធានជាតិ ស្របទៅតាមយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល"។

ថ្លែងក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ ឯកឧត្តម **ងី ច័ន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានគូសបញ្ជាក់យ៉ាងច្បាស់អំពីការស្វាគមន៍ និងការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគម្រោងបង្កើតសាលាអភិបាលកិច្ចនេះ ហើយលើកទឹកចិត្តឲ្យបង្កើនកិច្ចសហប្រតិបត្តិការគ្នាក្នុងភាពជាដៃឲ្យកាន់តែបានល្អប្រសើរដើម្បីឈានទៅសម្រេចបានរាល់កំណែទម្រង់ជាអាទិភាពរបស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍជាតិប្រកបដោយចីរភាព ។ ក្នុងនោះ ឯកឧត្តម បានលើកឡើងបន្ថែមទៀតថា "សាលាអភិបាលកិច្ចនេះ នឹងរួមចំណែកយ៉ាងធំធេងក្នុងការបង្កើនមូលធនសង្គម និងជាពិសេស បង្កើនភាពជាម្ចាស់ របស់រដ្ឋបានថ្នាក់ក្រោមជាតិ ដើម្បីឈានទៅសម្រេចយុទ្ធសាស្ត្រចតុកោណ ដំណាក់កាល

ទី៣ ដែលរួមមាន កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ហើយសាលានេះក៏ជាផ្នែកមួយ នៃការពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យផងដែរ"។


សម្រាប់ការធ្វើបទសម្ភាសន៍សូមទំនាក់ទំនង៖

លោក **ព្រាប កុល** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជាទូរស័ព្ទលេខ ០១២ ៨៧៧ ៨៣៣

ឬតាមរយអ៊ីម៉ែល kolpreap@ticambodia.org


###

*Transparency International is the civil society organisation leading the fight against corruption*